# លិខិតនិមន្ត និង អញ្ជើញពិធីបុណ្យកឋិនទានសាមគ្គី

យើងខ្ញុំព្រះករុណា ខ្ញុំបាទ នាងខ្ញុំ ជាគណៈកម្មការនាយកនៃសមាគមៈ សមាគមសាមគ្គីបារាំង-ខ្មែរប្រចាំក្រុងអ៊ិងស្បាំង សមាគមសិល្បៈបារាំង-ខ្មែរប្រចាំខេត្តប្លិរ្ស សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោមប្រចាំអឺរ៉ុប គណៈកម្មការ-អាចារ្យវត្តមង្គលសោភ័ណ្ឌ ពុទ្ធបរិស័ទ បានស្រុះស្រួលមូលមតិគ្នាជាឯកច្ឆន្ទប្រារព្ធពិធីបុណ្យកឋិនទានសាមគ្គីមួយដង្ហែចូលវត្តមង្គលសោភ័ណ្ឌប្រចាំខេត្តប្លិរ្ស ។

កាលបរិច្ឆេទៈ ថ្ងៃសៅរ៍ ទី១០ ខែ វិច្ឆិកា ព.ស.២៥៥៦ គ.ស.២០១២

នៅសាលបុណ្យៈ

Salle Charles de Rostaing
38 rue de l'Ecrevissière
41150 Onzain
Tél: 02 54 56 00 96; 06 52 49 57 16; 09 53 43 82 76; 06 65 01 03 48
E-mail: uoongsok@live.fr; Facebook: sokuoong

សូមប្រគេន និង ជំរាបថាៈ ក្នុងមួយត្រៃកំណត់ ៥០អឺរ៉ូ ។

## កម្មវិធីបុណ្យ

ថ្ងៃសៅរ៍ ទី១០ ខែ វិច្ឆិកា ព.ស.២៥៥៦ គ.ស.២០១២

ម៉ោង ០៩:០០នាទី ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ

ម៉ោង ១០:៣០នាទី នមស្សការព្រះរតនៈត្រៃ សមាទានសិល រាប់បាត្រ ព្រះសង្ឃសូត្រមន្ត វេរភត្តប្រគេនព្រះសង្ឃ

ម៉ោង ១២:០០នាទីថ្ងៃត្រង់ ភ្ញៀវកិត្តិយសជិតឆ្ងាយពិសារភោជនាហាររួមគ្នា

ម៉ោង ១៤:០០នាទី ដង្ហែប្រទក្សិណត្រៃចីវរជុំវិញសាលបុណ្យបីជុំរួចហើយយកមកដំកល់ទុកកណ្តាលជំនុំសង្ឃជាសង្ឃទានស្មោះរួចហើយវេរប្រគេនចំពោះសង្ឃដែលចាំព្រះវស្សាក្នុងវត្តមង្គលសោភ័ណ្ឌរួចហើយក៏និមន្តធម្មកថឹកសំដែងធម៌ទេសនារួចពីនោះទៀតព្រះសង្ឃធ្វើសង្ឃកម្មក្រាលគ្រងតាមព្រះវិន័យ..។ រួចពីនោះទៅក៏ប្រកាសលទផលការចូលបុណ្យកឋិនទានសាមគ្គីរួចនិមន្តព្រះសង្ឃបាចទឹកជយន្តោជាកិច្ចបញ្ចប់កម្មវិធីខាងសាសនា..។

**កម្មវិធីពេលល្ងាច**

ចាប់ពីម៉ោង ១៩:០០នាទីតទៅនឹងមានការជួបសប្បាយរីករាយជាមួយនិងសិល្បៈករ ដែលកំពុងពេញនិយមទើបនិងអញ្ជើញមកពីព្រះរាជាណាចក្រកម្ពុជារហូតដល់ម៉ោង ពីរភ្លឺ..។

សូមជំរាបថាៈ ម្ហូបនិងភេសជ្ជៈមានលក់នៅទីកន្លែងមានតម្លៃសមរម្យ ។
ក្លោងទ្វារចូលតាមសទ្ធាជ្រះថ្លា..។
សូមនិមន្ត និង អញ្ជើញ សូមអរគុណ ។

Courtesy Ven. Sok Uoong, E-mailuoongsok@live.fr